THE WORLD BANK
IBRD • IDA

Who We Are

**សេចក្តីប្រកាសព័ត៌មាន** | **20 មីនា 2020**

លើកកម្ពស់គណនេយ្យភាពសង្គម ក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗនៅប្រទេសកម្ពុជា

**ភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ —** ធនាគារពិភពលោកបានអនុម័តជំនួយឥតសំណងចំនួនពីរកញ្ចប់បំពេញបន្ថែមទៀត នៅថ្ងៃនេះ សម្រាប់គាំទ្រដល់គណនេយ្យភាពសង្គមនៅតាមផ្នែកសេវាសាធារណៈសំខាន់ៗមួយចំនួន មានដូចជា មណ្ឌលសុខភាព សាលាបឋមសិក្សា និងរដ្ឋបាលមូលដ្ឋានក្នុងខេត្តចំនួន១០ នៃប្រទេសកម្ពុជា។

បើទុកជាមានការកែលម្អបានប្រសើរឡើងច្រើនគួរសមហើយក្តីនូវលទ្ធភាពទទួលបានសេវាសាធារណៈនានានៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ គុណភាពរបស់សេវានេះនៅតែជាបញ្ហាប្រឈមមួយនៅឡើយ។ ការផ្តល់មតិដោយផ្ទាល់ពីសំណាក់អ្នកប្រើប្រាស់ដែលបានជ្រាបអំពីសេវាទាំងនេះ ជាពិសេសពីសំណាក់ពលរដ្ឋទូទៅតែម្តង គឺជាកត្តាសំខាន់មួយជំរុញឱ្យសេវាសាធារណៈនានាទទួលបានការកែលម្អគុណភាពកាន់តែប្រសើរឡើង នៅជុំវិញពិភពលោក។

កញ្ចប់ជំនួយឥតសំណងទីមួយ មានទឹកប្រាក់ចំនួន ៥,៩៥លានដុល្លារអាមេរិក ត្រូវបានអនុម័តផ្តល់ទៅឱ្យអង្គការទស្សនៈពិភពលោកអន្តរជាតិ (World Vision International) សម្រាប់ធ្វើសកម្មភាពនានាពាក់ព័ន្ធផ្នែកគណនេយ្យភាពសង្គម រួមមាន ការជ្រើសរើសអ្នកសម្របសម្រួលសហគមន៍ សម្រាប់ជួយជំរាបជូនប្រជាពលរដ្ឋអំពីសេវានានាដែលពួកគាត់មានសិទ្ធិទទួលបាន និងអំពីការប្រើប្រាស់មូលនិធិសាធារណៈ។ អ្នកសម្របសម្រួលនឹងរៀបចំធ្វើនូវតារាងពិន្ទុសម្រាប់ពលរដ្ឋធ្វើការវាយតម្លៃគុណភាពរបស់សេវាសាធារណៈ និងផ្តល់ការឯកភាពគ្នានៅលើផែនការសកម្មភាពរួមមួយចំនួនជាមួយអ្នកផ្តល់សេវា សម្រាប់កែលម្អគុណភាពរបស់សេវាបន្តទៀត។

កញ្ចប់ជំនួយឥតសំណងទីពីរ មានទឹកប្រាក់ចំនួន ១,៧២លានដុល្លារអាមេរិក ត្រូវបានផ្តល់ជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់ជួយពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវារដ្ឋាភិបាល នៅក្នុងការជូនព័ត៌មានដល់សាធារណជនអំពីការបំពេញមុខងារ និងការប្រើប្រាស់មូលនិធិដោយគណៈកម្មាធិការនេះ និងក្នុងការឆ្លើយតបឱ្យបានកាន់តែល្អឡើងទៅនឹងមតិយោបល់របស់ពលរដ្ឋ។

លោកស្រី **អ៊ីងហ្គូណា ដូប្រាចា ប្រធានគ្រប់គ្រងប្រចាំប្រទេសរបស់ធនាគារពិភពលោក** មានប្រសាសន៍ថា៖ *«ការពង្រឹងការចូលរួមរបស់ពលរដ្ឋ គឺជាចំណុចផ្តោតយកចិត្តទុកដាក់មួយនៅក្នុងចំណោមផ្នែកសំខាន់ៗនានានៅក្នុងឯកសារក្របខណ្ឌភាពជាដៃគូរបស់ធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា។ ធនាគារពិភពលោកបានចាត់ទុកក្របខណ្ឌគណនេយ្យភាពសង្គមរបស់រដ្ឋាភិបាលថាជាកិច្ចខិតខំទូទៅដ៏សំខាន់មួយ សម្រាប់បំពេញទៅលើការវិនិយោគក្នុងវិស័យអប់រំ, សុខាភិបាល, ការផ្គត់ផ្គង់ទឹកស្អាត និងសេវាដទៃទៀត តាមរយៈអភិក្រមជាលក្ខណៈប្រព័ន្ធនិងប្រកបដោយចីរភាព ដើម្បីប្រមែប្រមូលពលរដ្ឋឱ្យចូលរួមពាក់ព័ន្ធ និងពង្រឹងសមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ សំដៅធ្វើយ៉ាងណាតម្រូវឱ្យអ្នកផ្តល់សេវាមានគណនេយ្យភាពនៅក្នុងការបំពេញមុខងាររបស់ខ្លួន។»*

ជំនួយឥតសំណងទាំងពីរកញ្ចប់នេះ មានគោលបំណងទ្រទ្រង់ដល់ការអនុវត្តដំណាក់កាលទីពីរ នៃគម្រោងក្របខណ្ឌគណនេយ្យភាពសង្គម ដែលមានអាយុកាលពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ ក្របខណ្ឌនេះ គឺជាផ្នែកស្នូលមួយខ្វះមិនបាននៅក្នុងកម្មវិធីកែទម្រង់វិមជ្ឈការរបស់រដ្ឋាភិបាល ដែលសំដៅពង្រឹងការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ គម្រោងនេះ ជាគំនិតផ្តួចផ្តើមរួមរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ហើយស្ថិតក្រោមការចាត់ចែងរបស់គណៈកម្មាធិការដឹកនាំភាពជាដៃគូ (Partnership Steering Committee/PSC) ដែលមានក្រសួងមហាផ្ទៃ និងតំណាងរបស់អង្គការក្រៅរដ្ឋាភិបាល ជាសហប្រធាន។ គណៈកម្មាធិការនេះ មានសមាសភាពសមាជិករវាងតំណាងមកពីក្រសួងនានានៃរដ្ឋាភិបាល — មានក្រសួងមហាផ្ទៃ, អប់រំ យុវជន និងកីឡា, សុខាភិបាល, សេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឧស្សាហកម្ម និងសិប្បកម្ម, និងសាធារណការនិងដឹកជញ្ជូន — និងតំណាងសង្គមស៊ីវិល។

ឯកឧត្តម **ង៉ាន ចំរើន រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាប្រធាននៃលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** មានប្រសាសន៍ថា៖ *«រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តផ្នែកនយោបាយយ៉ាងមុតមាំក្នុងការអនុវត្តក្របខណ្ឌគណនេយ្យភាព ISAF នេះ ដើម្បីពង្រឹងសិទ្ធិអំណាចដល់ពលរដ្ឋ ពង្រឹងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងពលរដ្ឋ និងពង្រីកគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមទាំងនោះឱ្យកែលម្អការផ្តល់សេវាសាធារណៈ បានកាន់តែមានប្រសិទ្ធភាព។»* ឯកឧត្តមពោលបន្ថែមទៀតថា៖ *«ការពង្រីកវិសាលភាពគ្រប់ដណ្តប់របស់ ISAF នឹងកាន់តែបង្កើនសមត្ថភាពរបស់*

*រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែមានគណនេយ្យភាព និងក្នុងការឆ្លើយតបទៅតាមការវិវត្តន៍ប្រែប្រួលនូវសេចក្តីត្រូវការរបស់ពលរដ្ឋ និងវិស័យឯកជន នាពេលអនាគត។»*

គម្រោងនានានៅក្រោមភាពជាដៃគូនេះ មានវិសាលភាពគ្របដណ្តប់លើអ្នកផ្តល់សេវាសាធារណៈ ដែលរួមមាន សាលារៀននិងមណ្ឌលសុខភាព, ឃុំ សង្កាត់, ស្រុក និងរដ្ឋបាលក្រុង នៅក្នុងខេត្តចំនួន១០ គឺខេត្តបន្ទាយមានជ័យ, សៀមរាប, ព្រះវិហារ, កំពង់ធំ, កំពង់ឆ្នាំង, កណ្តាល, ព្រៃវែង, ស្វាយរៀង, កែប, និងព្រះសីហនុ។

លោក **ដានីញ៉ែល សែលវ៉ាណាយ៉ាហ្គាម នាយកអង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា** មានប្រសាសន៍ថា៖ *«ផ្អែកលើបទពិសោធន៍ និងសមិទ្ធផលដែលយើងសម្រេចបានក្នុងប៉ុន្មានឆ្នាំមកនេះ ខ្ញុំជឿជាក់ថា ជំនួយថ្មីនេះនឹងកាន់តែពង្រឹងបានថែមទៀតនូវការឆ្លើយតបរបស់សេវាសាធារណៈ ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវា។* លោកពោលបន្ថែមទៀតថា៖ *«ក្របខណ្ឌគណនេយ្យភាពសង្គមនេះ គឺជាយុគសម័យថ្មីមួយនៃការផ្តល់សេវាសាធារណៈ ដែលអមមកជាមួយនូវការលើកកម្ពស់ឱ្យមានកិច្ចសន្ទនាបែបស្ថាបនានៅតាមថ្នាក់មូលដ្ឋាន ដើម្បីធ្វើឱ្យមានការប្រែប្រួលយូរអង្វែងនៅក្នុងការផ្តល់សេវាសាធារណៈ ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ។»*

ជំនួយឥតសំណងទាំងពីរកញ្ចប់នេះគឺស្ថិតក្រោមការគ្រប់គ្រងដោយធនាគារពិភពលោក និងឧបត្ថម្ភហិរញ្ញវត្ថុដោយមូលនិធិមរតកសម្រាប់គណនេយ្យភាពសង្គម និងការផ្តល់សេវានៅកម្ពុជា (Cambodia Social Accountability and Service Delivery Trust Fund) ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលអាល្លឺម៉ង់ និងស្វីស។

ព័ត៌មានផ្សេងទៀតអាចរកមើលបាននៅលើវេបសាយ៖ www.worldbank.org/cambodia

ហ្វេសប៊ុក៖ http://www.facebook.com/worldbank

ធ្វីតធឺរ៖ http://www.twitter.com/worldbank

កាណាល់យូធូប៖ http://www.youtube.com/worldbank

---

**សេចក្តីប្រកាសព័ត៌មានលេខ 2020/03/20**

---

ទំនាក់ទំនង

**នៅភ្នំពេញ**

លោក ប៊ូ សារឿន តាមរយ
(855 12) 414 088
sbou@worldbank.org

About
Data
Research and Publications
Learning
News
Projects and Operations
Countries
Topics

FOLLOW US

NEWSLETTER

Enter email to subscribe...

This Site in: ENGLISH

Legal | Access to Information | Jobs | Contact

REPORT FRAUD OR CORRUPTION

WORLD BANK GROUP | IBRD IDA IFC MIGA ICSID

© 2020 The World Bank Group, All Rights Reserved.